## អ្វីទៅហៅ ADR?

### ចម្លើយយ៉ាងរហ័ស

*ពេលណាត់ជួប គឺធម្មតាអាចធ្វើបានក្នុងរយៈ បី ថ្ងៃ ទៅ ពីរ សប្តាហ៍ ។*

### មិនយកតម្លៃ

*គ្មានទាមទារតម្លៃទេ ដែលប៉ះពាល់មកលើ ការជម្រើសទាំងឡាយណាមួយ ។*

### ការរក្សាទុកជាភាពសម្ងាត់

ព័ត៌មានចែកទៅកាន់កន្លែងក្រៅផ្សេងៗ គឺ ប្រើសម្រាប់ពេលដែល "ត្រូវការដឹង" តែប៉ុណ្ណោះ ។

### ការការពារសិទ្ធិស្របច្បាប់

គ្មានអ្នកណាម្នាក់លះបង់ចោលសិទ្ធិរបស់គេ សម្រាប់ស្វែងរកដំណោះស្រាយផ្លូវច្បាប់ នោះទេ បើសិនជាគេគ្មានការពេញចិត្តអំពី លទ្ធផលមកពីយុទ្ធសាស្រ្ត ADR ។

### ការផ្តោតមកលើលទ្ធផលប៉ងប្រាថ្នា

*កិច្ចព្រមព្រៀងសរសេរ គឺរាប់បញ្ចូលទៅក្នុង ឯកសារ IEP ដោយមានការផ្តល់ជំនួយផ្គត់ផ្គង់សម្រាប់ធ្វើការឃ្លាំមើលអំពីភាពលូតលាស់ ។*



LONG BEACH UNIFIED SCHOOL DISTRICT

សម្រាប់ការទទួលព័ត៌មានបន្ថែម ឬ សម្រាប់ ដំណោះស្រាយប្រើជំនួសមកលើការប្រឆាំង តវ៉ា គឺសូមបើកអានមើលនៅតាម https://www.lbschools.net/Departments/Special_Education/alt_dispute_resolution.cfm ឬ ទាក់ទង Ariana Zambada តាម azambada@lbschools.net ឬ លេខទូរស័ព្ទ (562) 997-8005 ។

LONG BEACH UNIFIED SCHOOL DISTRICT



# ដំណោះស្រាយប្រើជំនួសមកលើការប្រឆាំងតវ៉ា (ADR)

*ការនាំក្រុមគ្រួសារ និងអ្នកអប់រំមករួមគ្នា ដើម្បីធ្វើការគាំទ្រទៅកាន់លទ្ធផលជោគជ័យផ្ទាល់ខ្លួន និងផ្នែកប្រាជ្ញានៃសិស្សរាល់រូប រាល់ថ្ងៃ ។*

ការិយាល័យ SELPA នៃក្រសួងអប់រំ ឱស្រ្ទីត ឡុងប៊ីច ផ្តល់ជាសមាជិកក្នុងក្រុមនៃកម្មវិធីសិក្សាដោយឡែកសម្រាប់សិស្ស (IEP) ដោយមានយុទ្ធសាស្រ្តជាដំណោះស្រាយសម្រាប់ប្រើជំនួសមកលើការប្រឆាំងតវ៉ា (ADR) នៅពេលណាមានភាពមិនយល់ស្របគ្នា ដែលធ្វើអោយពន្យារពេលដល់ការសម្រេចនៅក្នុងកិច្ចប្រជុំ IEP ។ ជម្រើសផ្សេងៗអំពី ADR គឺទាក់ទងការប្រើបុគ្គលិកមានសមត្ថភាពត្រឹមត្រូវជាអ្នកកណ្តាល ដែលពួកគេជួយណែនាំក្រុមតាមរយៈប្រើយុទ្ធសាស្រ្តយ៉ាងជាក់លាក់សម្រាប់បន្ធូរទៅតាមដំណោះស្រាយជារបៀបឆ្នៃប្រឌិត ស្របច្បាប់ និងបង្រួបបង្រួមគ្នា ។ នៅពេលបន្ទាប់ទៅ គឺសមាជិកក្នុងក្រុម IEP រៀនបង្កើតជាទំនាក់ទំនងតាមការបើកចំហ និងជួយបន្ធូរទៅវិញអំពីទំនាក់ទំនង ដែលបានទទួលការខូចខាត ដោយនៅពេលជាមួយគ្នា គឺរៀបចំជាគម្រោងកាន់តែមាំមួនឡើងសម្រាប់សិស្សដែលត្រូវការជំនួយពិសេសអំពីផ្នែកសិក្សា ។ តាមរយៈដំណោះស្រាយ ADR គឺក្រុម IEP ទីបំផុត បានទទួលការគ្រប់គ្រងឡើងវិញអំពីដំណើរការធ្វើការសម្រេច ជាជាងបោះបង់ចោលមុខងារទៅកាន់ភ្នាក់ងារសវនាការ ឬ ចៅក្រម ដែលធ្វើការបញ្ជាមកលើដំណោះស្រាយមួយមុខ និងតែមួយមុខប៉ុណ្ណោះ ដោយពួកគាត់មិនទាំងធ្លាប់បានជួបសិស្ស ឬ មើលឃើញផ្ទាល់ផងអំពីសិទ្ធិជម្រើសផ្សេងៗនៅក្នុងថ្នាក់ ។

### **ដំណាក់ការ 1**

មាតាបិតា ឬ បុគ្គលិក ឱស្រ្ទីត អាចធ្វើការស្នើសុំដំណោះស្រាយ ADR ពីក្រសួងអប់រំ ឱស្រ្ទីត ឡុងប៊ីច បានដោយគ្មានទាមទារអោយបង់អ្វីសោះទៅកាន់ក្រុមទាំងសងខាងដែលជាប់ទាក់ទង ។ អ្នកសម្របសម្រួលកម្មវិធី ADR នឹងប្រមូលផ្តុំអំពីព័ត៌មានមកពីក្រុមជាប់ទាក់ទង និងធ្វើការបញ្ជាក់អំពីបញ្ហាផ្សេងៗ រួមទាំងធ្វើការដោះស្រាយស្របតាមបញ្ហាកង្វល់ ឬ សេចក្តីត្រូវការ ។

### **ដំណាក់ការ 2**

អ្នកសម្របសម្រួលកម្មវិធី ADR ធ្វើការសើរើសំណុំរឿងអំពីបញ្ហាជម្លោះ ដើម្បីប្រមូលផ្តុំអំពីព័ត៌មាន និងផ្តល់ជាការវិភាគអំពីចំណុចប៉ះពាល់ជម្លោះក្នុងបច្ចុប្បន្ន ។ ក្នុងនាមជាក្រុមទីបី គឺការយល់ឃើញ ឬ យោបល់ថ្មីៗប្រហែលជាអាចបង្កើតលទ្ធផលបាន ។

### **ដំណាក់ការ 3** *(បើត្រូវការ)*

អ្នកគ្រប់គ្រងកម្មវិធីអប់រំពិសេស ឬ បុគ្គលិកផ្សេងប្រចាំ LBUSD ប្រហែលជាត្រូវបានទទួលការស្នើសុំមកពីអ្នកសម្របសម្រួលកម្មវិធី ADR ដោយមានសេចក្តីអនុញ្ញាតពីមាតាបិតាសម្រាប់ធ្វើការពិនិត្យមើលនៅក្នុងបន្ទប់រៀន ។ ដំណើរការនេះផ្តល់ជាឱកាសសម្រាប់ធ្វើការស្វែងរកជាបន្ថែមអំពីបញ្ហាជម្លោះ ដោយមូលហេតុថា អ្នកសម្របសម្រួលកម្មវិធី ADR បំពេញកិច្ចការជាមួយក្រុមរួមចំណែកទាំងអស់ ដើម្បីទទួលយកដំណោះស្រាយមកលើជម្លោះ ។

### **ដំណាក់ការ 4**

បើសិនជាជម្លោះមិនទាន់ដោះស្រាយចេញ គឺកិច្ចប្រជុំជាផ្លូវការមួយនឹងរៀបចំធ្វើ ។ នេះអាចមានជាកិច្ចប្រជុំសម្រាប់ដំណោះស្រាយ ឬ កិច្ចប្រជុំជាមួយក្រុម IEP និងរាប់បញ្ចូលផងទាំងការជួបគ្នាមុនម៉ោងសម្រាប់ត្រៀមទុក រួមទាំងកិច្ចការធ្វើតាមជាបន្តបន្ទាប់ទៅទៀត ។ អ្នកសម្របសម្រួលកម្មវិធី ADR ប្រកាសហៅអ្នកគ្រប់គ្រងកម្មវិធីអប់រំពិសេស ឬ បុគ្គលិកផ្សេងប្រចាំ LBUSD អោយធ្វើជាអ្នកកណ្តាលក្នុងការធ្វើបញ្ជាក់អំពីរបៀបវារៈ និងលទ្ធផលពីកិច្ចប្រជុំ ទាមទារអោយមានកិច្ចព្រមព្រៀង ជួយក្រុមអោយធ្វើការផ្តោតមកលើដំណោះស្រាយ និងដំណើរការ ធ្វើការជម្រុញអោយមានជាចម្លើយមកលើបញ្ហា ឃ្លាំមើលម៉ោង និងសរសេរកត់ទុកអំពីលទ្ធផលផ្សេងៗ ដែលត្រូវបានទទួលស្របតាមការយល់ព្រមរួមគ្នា ការបានចុះហត្ថលេខា IEP ឬ ឯកសារបញ្ជាក់អំពីកិច្ចព្រមព្រៀងគ្នា ។

### **ធនធានសម្រាប់មាតាបិតា**

LBUSD បានបង្កើតប្រព័ន្ធផ្សព្វផ្សាយសង្គមយ៉ាងជាក់លាក់មួយ ហៅ @LBUSDspecialeducationresource ដើម្បីផ្តល់ការផ្គត់ផ្គង់ទៅកាន់ដំណាក់ការ 1 នៃគម្រោង ADR លើកបង្ហាញអំពីយុទ្ធសាស្រ្ត ADR និងធនធានអំពីកម្មវិធីអប់រំពិសេសទៅកាន់មាតាបិតា និងបុគ្គលិកក្នុង LBUSD ។

ធនធានអំពីកម្មវិធីអប់រំពិសេសក្នុង LBUSD មានគោលដៅបង្កើតជាទំនាក់ទំនងជាមួយសហគមន៍ ដើម្បីបង្កើនជំនឿទុកចិត្ត ។ សូមធ្វើការតាមដានជាមួយយើងខ្ញុំនៅតាម @LBUSDspecialeducationresource លើ អ៊ីនស្តាហ្គ្រាម Instagram និង ធ្វីទ័រ Twitter ដើម្បីទទួលនូវព័ត៌មានថ្មីៗ តាមរយៈការតាំងបង្ហាញរបស់យើងខ្ញុំ និងសកម្មភាពទាក់ទងអំពីទំនាក់ទំនងជាមួយសហគមន៍ ការដោះស្រាយបញ្ហាផ្សេងៗ ការផ្តល់ជាធនធានសម្រាប់កម្មវិធីអប់រំពិសេស និងអ្វីជាច្រើនបន្ថែមទៀត ។

LBUSDSpecialEducationResource
@LBUSDSPED

@LBUSDSpecialEducationResource